ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ៖ ១១៩
ចុះថ្ងៃទី១៣-០២-២០១៣
សាលដីកា
លេខ៖ ៦៣ ក្រVI«វ»
ចុះថ្ងៃទី ២៩-១១-២០១៣

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតតាមច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឲ្យប្រើតាមក្រិត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨-០២-១៩៩៣ បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នៅថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០១៣ ដោយមានសមាសភាពដូចតទៅ៖

**សមាសភាពក្រុមប្រឹក្សាជំនុំជំរះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

លោកស្រី ហ៊ិន សុគន្ធា

ដើម្បីជំនុំជំរះលើបណ្ដឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ៖ ១១៩ / ១៣-០២-២០១៣ រវាង៖

១-ជនជាប់ចោទឈ្មោះ [redacted] ជា ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិឈើទាល ឃុំឈូក ខេត្តកំពត ទីលំនៅសព្វថ្ងៃ [redacted] សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ មុខរបរធ្វើស្រែ ឪពុកឈ្មោះ [redacted]«វ» ម្ដាយឈ្មោះ[redacted]«ស» ប្រពន្ធឈ្មោះ [redacted]«រ» ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី១២-៣-២០១១(មទ) ។

២-ជនជាប់ចោទឈ្មោះ [redacted] ធី ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិស្វាយអញ្ចិត ឃុំស្វាយអញ្ចិត ស្រុកជុំគិរី ខេត្តកំពត ទីលំនៅសព្វថ្ងៃ [redacted] ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ មុខរបរ កម្មករ ឪពុកឈ្មោះ [redacted]«រ» ម្ដាយឈ្មោះ [redacted]«រ» ប្រពន្ធឈ្មោះ [redacted]«រ» ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី១២-៣-២០១១(មទ) ។

៣-ជនជាប់ចោទឈ្មោះ [redacted] ម៉ាប់ ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើត ភូមិស្វាយអញ្ចិត ឃុំស្វាយអញ្ចិត ស្រុកជុំគិរី ខេត្តកំពត ទីលំនៅ [redacted] ផ្លូវលំ ភូមិត្រពាំងពោធិ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ មុខរបរ កម្មករសំណង់ ឪពុកឈ្មោះ [redacted] «រ» ម្តាយឈ្មោះ [redacted] «រ» នៅលីវ ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី១២-៣-២០១១(មឲ) ។

-លោក ផៃ វិបុល ជាមេធាវីការពារសិទ្ធិជនជាប់ចោទ ។

<u>ត្រូវចោទពីបទៈ</u> អំពើលួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ខេមរា ភេទប្រុស អាយុ ២៨ឆ្នាំ ជាតិខ្មែរ ទីលំនៅ ផ្ទះជួល សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

<u>ឯរឿងហេតុមានដូចតទៅៈ</u>

កាលពីថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០១១ វេលាម៉ោង ១៥,៣០នាទី ឈ្មោះ [redacted] ខេមរា ភេទប្រុស អាយុ ២៨ឆ្នាំ បានជិៈម៉ូតូមួយគ្រឿងម៉ាកហុងដាសេ ១២៥ ពណ៌ខ្មៅ មានលេខតួ និងលេខម៉ាស៊ីន ៨៨៧៨២៨១ ទៅលេងផ្ទះប្រពន្ធនៅភូមិត្រពាំងពោធិ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជាធានីភ្នំពេញ ។ ពេលទៅដល់ឈ្មោះ [redacted] ខេមរា បានចតម៉ូតូទុកមុខបន្ទប់ទឹកក្រោយផ្ទះ ដោយបានចាក់សោរត្រឹមត្រូវ រួចចូលទៅក្នុងផ្ទះបាត់ ។ ស្រាប់តែឈ្មោ [redacted] ជា [redacted] ធី និងឈ្មោះ [redacted] ម៉ាប់ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន និងដកហូតបានម៉ូតូម៉ាកហុងដាសេ ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១០ មានលេខតួ និងលេខម៉ាស៊ីន ៨៨៧៨២៨១ របស់ឈ្មោះ [redacted] ខេមរា ។

-បានឃើញសាលក្រមលេខ ១០១«កប៥» ចុះថ្ងៃទី ១៧-១០-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចសេចក្តីដូចខាងក្រោម ៖

១-ផ្តន្ទាទោសៈ

ក-ឈ្មោះ [redacted] ជា ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ

ខ-ឈ្មោះ [redacted] ធី ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ

គ-ឈ្មោះ [redacted] ម៉ាប់ ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗចំនួន ០៣ឆ្នាំ(បីឆ្នាំ) ពីបទៈ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហឹង្សា ប្រព្រឹត្តនៅភូមិត្រពាំងពោធិ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

២-វត្ថុតាងមាន៖

ក-ម៉ូតូមួយគ្រឿងម៉ាកហុងដាសេ ១២៥ ពណ៌ខ្មៅ មានលេខតួ និងលេខម៉ាស៊ីន ៨៤៧៨២៤១ តាមកំណត់ហេតុប្រគល់ម៉ូតូបណ្ដោះអាសន្នចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ២០១១ របស់ការិយាល័យព្រហ្មទណ្ឌ កំរិតស្រាល ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ ។

ខ-សោទីបលេខ ៨ រាងអក្សរ L ចំនួនមួយ , ដែកកាច់រាងសំប៉ែតចំនួនមួយ ដូចក្នុងកំណត់ហេតុទទួលវត្ថុតាងលេខ ២៣០ អយត ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ២០១១ ត្រូវរឹបអូស បំផ្លាញចោល ។

-សាលក្រមនេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០១១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទ , មេធាវីការពារជនជាប់ចោទ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី បើកផ្លូវប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាជំនុំជំរះសង្ខេបរបាយការណ៍រឿង

-ជនជាប់ចោទឈ្មោះ [redacted]ជា (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] ម៉ាប់ (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted]ធី (វត្តមាន)

-លោក[redacted]វិបុល ជាមេធាវីការពារសិទ្ធិ (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted]ធី ថា៖ ខ្ញុំបានយកដែកអក្សរតេកាច់សោរម៉ូតូគេ ហើយប៉ូលីសចាប់បាននៅផ្ទះជួល ។

-ជនជាប់ចោទឈ្មោះ [redacted] ជា ថា៖ ខ្ញុំបានជិះម៉ូតូទៅជាមួយគេដែរ ។

-ជនជាប់ចោទឈ្មោះ [redacted] ម៉ាប់ ថា៖ ខ្ញុំក៏បានជិះម៉ូតូទៅជាមួយគេដែរ ។

ពួកខ្ញុំទទួលស្គាល់ថា បានលួចម៉ូតូគេមែន ។ សុំមេត្តាលើកលែងទោសដល់ពួកខ្ញុំផង ។

តំណាងមហាអយ្យការធ្វើសេចក្ដីសន្និដ្ឋាន

សុំតម្កល់សាលក្រមទុកជាបានការ ។

មេធាវីធ្វើសេចក្ដីសន្និដ្ឋាន

កូនក្ដីខ្ញុំបានសារភាពអស់ហើយ ចំពោះម៉ូតូដែលជាវត្ថុតាងនៃបទល្មើសក៏បានប្រគល់ឲ្យម្ចាស់វិញ។ សូមលោកប្រធានមេត្តាសម្រេចតាមមាត្រា ៩៣, ៩៤ ។

តុលាការថយទៅពិភាក្សា

-ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ ។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវី ។

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ និងសំណូមពរ ។

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

សាលាឧទ្ធរណ៍

យល់ឃើញថា៖

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៨-១១-២០១១ របស់លោក [redacted] វាសនា មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ធី ,ឈ្មោះ [redacted] ម៉ាប់ និងបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៦-១១-២០១១ របស់ជនជាប់ចោទឈ្មោះ ខាន់ ជា ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ៖ ១០១ កប/៥ ចុះថ្ងៃទី ១៧-១០-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល បានធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សភាព្រហ្មទណ្ឌទទួលជំនុំជំរះបាន ។

២-តាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោលឃើញថា៖ កាលពីថ្ងៃទី ០៦-៣-២០១១ វេលាម៉ោង ១៥,៣០នាទី ជនជាប់ចោទឈ្មោះ [redacted] ជា , ឈ្មោះ [redacted] ធី និងឈ្មោះ [redacted] ម៉ាប់ ពិតជាបានប្រើដែកអក្សរ T គាស់ទម្លុះទម្លាយ កាច់សោរ ក លួចយកម៉ូតូរបស់ជនរងគ្រោះប្រាកដមែន ដែលជាទម្រង់មួយនៃអំពើមានជាតុផ្សំ និងភស្តុតាងដាក់បន្ទុកលើជនជាប់ចោទពីបទ៖ អំពើលួចមានស្ថានទម្ងន់ទោស ដោយសារការប្រព្រឹត្តអំពើហឹង្សា ប្រព្រឹត្តនៅភូមិត្រពាំងពោធិ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៦-៣-២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និង ៣៥៧ នៃក្រមព្រហ្មទណ្ឌ ដូចមានខ្លឹមសារក្នុងផ្នែកសំអាងហេតុនៃសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញបញ្ជាក់ស្រាប់ ហើយដែលសភាព្រហ្មទណ្ឌឯកភាពលើសំអាងហេតុទាំងនេះ ។ ដូចនេះ សភាព្រហ្មទណ្ឌមិនចាំបាច់លើកយកសំអាងហេតុដដែលនេះមកបញ្ជាក់ជាថ្មីទៀតទេ ។

៣-តាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍៖ បានប្តឹងសុំឲ្យសភាព្រហ្មទណ្ឌតម្កល់សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការ ដោយលើកហេតុផលថាសេចក្តីសម្រេចនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ ។ ចំណុចនេះគប្បីសភាព្រហ្មទណ្ឌពិចារណា ។

៤-ជនជាប់ចោទទាំងបីបានសំណូមពរ សុំឲ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ។ ប៉ុន្តែសាលក្រមសាលាដំបូងរាជធានីភ្នំពេញបានសម្រេចផ្តន្ទាទោសជនជាប់ចោទទាំងបីដាក់ពន្ធនាគារក្នុងម្នាក់ៗចំនួនបីឆ្នាំ ឃើញថា៖ ការផ្តន្ទាទោសទោសនេះស្ថិតក្នុងកំរិតអប្បរមាហើយ ដូចនេះសភាព្រហ្មទណ្ឌមិនអាចបន្ធូរបន្ថយទោសបានទៀតទេ ។

៥-សាលក្រមព្រហ្មទណ្ឌលេខ ១០១ កប៥ ចុះថ្ងៃទី ១៧-១០-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ គប្បីតម្កល់ទុកជាបានការ។

<u>ហេតុដូច្នេះ</u>

<u>វិនិច្ឆ័យសេចក្តី</u>

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៨-១១-២០១១ របស់លោក [redacted] វាសនា និងបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៦-១១-២០១១ របស់ឈ្មោះ [redacted] ា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១០១ កប៥ ចុះថ្ងៃទី ១៧-១០-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៣-សាលដីកានេះជំនុំជំរះថ្ងៃទី ១៣-១១-២០១៣ និងប្រកាសជាសាធារណៈថ្ងៃទី ២៩-១១-២០១៣ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ។

បើកសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធជួយសហការអនុវត្តសាលដីកានេះអោយបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា៖ [redacted] | ហត្ថលេខា៖ [redacted] | ហត្ថលេខា៖ [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ,ថ្ងៃទី [illegible] ខែ មិនា ឆ្នាំ២០១៤
ក្រឡាបញ្ជី

[redacted]